## ជនគ្មានសញ្ជាតិ (Stateless Person)

ជនគ្មានសញ្ជាតិ ជាបុគ្គល ដែលគ្មានសញ្ជាតិនៃប្រទេសណាមួយ។ ជនប្រភេទនេះ មានពីរប្រភេទ គឺគ្មានសញ្ជាតិពិតប្រាកដ (*de jure*) និង គ្មានសញ្ជាតិជាក់ស្តែង (*de facto*) ដែលសំដៅលើបុគ្គលមានសញ្ជាតិ ក៏ប៉ុន្តែមិនបានប្រាស្រ័យការការពារពីរដ្ឋាភិបាល។ ការបាត់សញ្ជាតិ មានចរិតពីរប្រភេទ គឺដាច់ខាត និងធម្មតា ដែលបាត់សញ្ជាតិក្រោយកំណើត និង មិនបានទទួលសញ្ជាតិនៅពេលមានកំណើត (ដាច់ខាត)។ មានការបាត់សញ្ជាតិជាបុគ្គល និងជាក្រុមផងដែរ (mass stateless)។

មានមូលហេតុជាច្រើន ដែលនាំឲ្យគ្មានសញ្ជាតិ ឬបាត់សញ្ជាតិ។ វាអាចបណ្តាលមកពីកត្តាសង្គម ឬបញ្ហាច្បាប់ (ទំនាស់រវាងច្បាប់ស្តីពីសញ្ជាតិ)។ ករណីបុគ្គល មានចំពោះការរៀបអាពាហ៍ពិពាហ៍។ បុគ្គលរៀបការជាមួយជនបរទេស ត្រូវលះបង់សញ្ជាតិខ្លួនឯង ហើយក្រោយពេលលែងលះ គាត់បានបាត់សញ្ជាតិ។ ក្នុងករណីជាក្រុម វាអាចកើតឡើងដោយ ការប្តូរដែនដី ឬច្បាប់ បានចែងដកសញ្ជាតិជាក្រុមពីក្រុមមនុស្សណាមួយ។ ជាក់ស្តែង ក្រោមរបប អ៊ីត្លែរ  មេដឹកនាំនេះ បានចេញក្រឹត្យ ដកសញ្ជាតិអាឡឺម៉ង់ពីជនជាតិអាឡឺម៉ង់ដើមកំណើតជ្វីប។

បុគ្គលគ្មានសញ្ជាតិ ទទួលរងនូវហានីភ័យជាច្រើន ដោយសារគាត់ មិនអាចទទួលបានការការពារតាមផ្លូវទូត គ្មានសិទ្ធិមួយចំនួន ឬត្រូវបានបណ្តេញពីដែនដី។ អាស្រ័យហេតុនេះ សហគមអន្តរជាតិ បានរួមគ្នា អនុវត្តវិធានចំនួនពីរ គឺការលុបភាពគ្មានសញ្ជាតិ និង ការកាត់បន្ថយភាពគ្មានសញ្ជាតិ។ វិធានការនេះក្នុងទម្រង់ជា ច្បាប់ឬ សន្ធិសញ្ញា។ ចាប់ផ្តើមពីឆ្នាំ ១៩៣០ មានអនុសញ្ញាស្តីពីបញ្ហាមួយចំនួនពាក់ព័ន្ធទំនាស់នៃច្បាប់សញ្ជាតិ។ ឆ្នាំ១៩៤៨ ក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៥ ចែងហាមឲ្យដកសញ្ជាតិដោយបំពាន។ ឆ្នាំ១៩៦១ អនុសញ្ញាចំប្រធានមួយ គឺការបន្ថយភាពគ្មានសញ្ជាតិ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ (UN Doc. A/CONF.9/15)។ ក្នុងនេះក៏បានចែងហាមផងដែរ នូវការដកសញ្ជាតិ ដែលអាចនាំឲ្យក្លាយជាបុគ្គលគ្មានសញ្ជាតិ។ ក្រោមមកក្នុងឆ្នាំ ១៩៥៧ អង្គការសហប្រជាជាតិ បានអនុម័ត Convention on the Nationality of Married Women ដើម្បីជួយកាត់បន្ថយស្ត្រីកុំឲ្យមានការបាត់សញ្ជាតិ ដោយសារការរំលាយអាពាហ៍ពិពាហ៍។ ជាចុងក្រោយ អនុសញ្ញាស្តីពីជនភៀសខ្លួន ដែលពាក់ព័ន្ធដោយប្រយោលសម្រាប់ជួយបន្ថយការបាត់បង់សញ្ជាតិ (Encyclopedia of PIL by Max Planck, pp. 656-660)។